# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខៈ ១៩៤ សជណ ប.ស្ក

## សារាចរណែនាំ
## ស្តីពី
## ការដាក់ចេញនូវវិធានការសម្រាប់កិច្ចគាំពារបរិស្ថានពីប្រភពរោងចក្រ

ក្រសួងបរិស្ថាន បានពិនិត្យឃើញថា រោងចក្រ សហគ្រាសមួយចំនួនធំបានយកចិត្តទុកដាក់ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន។ ទន្ទឹមនឹងនោះដែរ ក៏មានរោងចក្រសហគ្រាស មួយចំនួនតូចនៅពុំទាន់បានយកចិត្តទុកដាក់អនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាននៅឡើយ ហើយបានបង្កការបំពុលបរិស្ថានម្តងហើយម្តងទៀត ទោះបីជាទទួលបាននូវការព្រមាន និងពិន័យអន្តរការណ៍ពីក្រសួងបរិស្ថានជាបន្តបន្ទាប់ក៏ដោយ។

ដើម្បីពង្រឹងការអនុវត្តច្បាប់ និងទប់ស្កាត់ផលប៉ះពាល់ដល់សុខភាពសាធារណៈនិងបរិស្ថានពីការបញ្ចេញសំណល់រឹង រាវ និងឧស្ម័នពីប្រភពរោងចក្រ សហគ្រាស សំដៅលើកកម្ពស់កិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្រសួងបរិស្ថាន ដោយបានការអនុញ្ញាតពីរាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារអចិន្ត្រៃយ៍អន្តរក្រសួង សម្រាប់អនុវត្តការងារដោះស្រាយបញ្ហាពាក់ព័ន្ធការបំពុលបរិស្ថានពីប្រភពរោងចក្រ ដោយមានការចូលរួមពីតំណាង ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ តាមរយៈក្រុមការងារអចិន្ត្រៃយ៍អន្តរក្រសួងនេះ ក្រសួងបរិស្ថាន បានសម្រេចដាក់ចេញនូវវិធានការចំនួន ៦ ជំហាន ដល់ម្ចាស់រោងចក្រសហគ្រាសដែលបានបង្កការបំពុលបរិស្ថាន មានដូចខាងក្រោមៈ

**ជំហានទី ១.** ធ្វើការពិន័យអន្តរការណ៍ដល់ម្ចាស់រោងចក្រ តាមកំហុសជាក់ស្តែង និង/ឬផ្អាកការអនុញ្ញាតនាំចូលវត្ថុធាតុដើមដោយពន្ធជាបន្ទុករបស់រដ្ឋ ឬផ្អាកដំណើរការអាជីវកម្មជាបណ្តោះអាសន្ន ឬជាស្ថាពរ។

**ជំហានទី ២.** ធ្វើការអប់រំ និងណែនាំដល់ម្ចាស់រោងចក្រឱ្យធ្វើការកែតម្រូវតាមលក្ខណៈបច្ចេកទេសនូវផ្នែកផលិតកម្មរបស់រោងចក្រ ដែលបានបង្កការបំពុលបរិស្ថាន។

**ជំហានទី ៣.** បញ្ជូនក្រុមមន្ត្រីជំនាញបច្ចេកទេសទៅជួយណែនាំម្ចាស់រោងចក្រ ដើម្បីធ្វើការកែតម្រូវតាមលក្ខណៈបច្ចេកទេសនូវផ្នែកផលិតកម្មរបស់រោងចក្រ ដែលបានបង្កការបំពុលបរិស្ថាន។

**ជំហានទី ៤.** ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះរោងចក្រ និងឈ្មោះម្ចាស់រោងចក្រ ដែលមិនគោរពតាមបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធបរិស្ថាននានាដែលមានជាធរមាន។

**ជំហានទី ៥.** បញ្ចូលឈ្មោះរោងចក្រ និងម្ចាស់រោងចក្រចូលក្នុងបញ្ជីក្រុមរោងចក្រដែលបង្កការបំពុលបរិស្ថាន។

**ជំហានទី ៦.** ប្រើប្រាស់យន្តការតុលាការឱ្យម្ចាស់រោងចក្រសងការខូចខាតបរិស្ថាន តាមការគណនាទំហំជាក់ស្តែងចាប់ពីថ្ងៃដែលបានប្រព្រឹត្តកន្លងមក។

ទទួលបានសារាចរណែនាំនេះ សូមម្ចាស់រោងចក្រ សហគ្រាសទាំងអស់មេត្តាជ្រាប និងត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវខ្លឹមសារលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។ ក្នុងករណី ម្ចាស់រោងចក្រ សហគ្រាស នៅតែបង្កការបំពុលបរិស្ថានបន្តទៀត ក្រសួងបរិស្ថាននឹងអនុវត្តវិធានការដូចបានកំណត់ខាងលើ និងវិធានការច្បាប់៕

រាជធានីភ្នំពេញ ថ្ងៃទី០៣ខែ មីនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារដ្ឋបាលរាជធានី ខេត្ត
- មន្ទីរបរិស្ថានរាជធានី ខេត្ត
- សមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជាGMAC
- ឯកសារ កាលប្បវត្តិ